ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
និងអតីតយុទ្ធជន

លេខ ០១ សកអ/៩៨

ភ្នំពេញ ថ្ងៃទី ១៩ ខែមករា ឆ្នាំ១៩៩៨

# ប្រកាសរួម

## ស្ដីពីការពិនិត្យកាយសម្បទាជាចាំបាច់
## ជនកម្ពុជានិងជនបរទេសដែលមកប្រកបមុខរបរនៅព្រះរាជាណាចក្រកម្ពុជា

រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន
រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣
- បានឃើញច្បាប់ការងារដែលប្រកាសអោយប្រើតាមក្រឹត្យ លេខ៥៩ក្រ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧

## សម្រេច

ប្រការ១: ជនកម្ពុជា និងជនបរទេស ទាំងពីរភេទ ដែលប្រកបមុខរបរណាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុង មាត្រាទី១ នៃច្បាប់ការងារ ចាំបាច់ត្រូវឆ្លងការពិនិត្យ កាយសម្បទា ។

ប្រការ២: នាយកដ្ឋានពេទ្យការងារ នៃក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន មានភារកិច្ចពិនិត្យកាយសម្បទានិងកំណត់ បែបបទ និងលក្ខណៈបច្ចេកទេស នៃការពិនិត្យ កាយសម្បទា ។

ប្រការ៣: មុនពេលប្រកបមុខរបរ ជនកម្ពុជា និងជនបរទេសទាំងនោះ ត្រូវទៅពិនិត្យកាយសម្បទាជាចាំបាច់ នៅនាយកដ្ឋានពេទ្យការងារ ដែលស្ថិតនៅអាគារលេខ៤៨ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែ ស្រុកមានជ័យ រាជធានីភ្នំពេញ ។

ប្រការ៤: ចំពោះជនកម្ពុជា និងជនបរទេស ដែលបានចូលធ្វើការរួចហើយ មុនប្រកាសនេះចេញផ្សាយ ក៏ត្រូវពិនិត្យ កាយសម្បទា នៅនាយកដ្ឋានពេទ្យការងារនេះដែរ ។

ប្រការ៥: ការពិនិត្យកាយសម្បទា អាចមានការពិនិត្យ ជាលក្ខណៈពិសេសថែមទៀត តាមមុខជំនាញ ឬតាមករណីជាក់ស្ដែង ។

ប្រការ៦: ក្រោយពីពេលធ្វើការពិនិត្យកាយសម្បទា បានសព្វគ្រប់ត្រឹមត្រូវហើយនោះ ប្រធានមណ្ឌលពេទ្យការងារ ចេញ វិញ្ញាបនបត្រ បញ្ជាក់ការពិនិត្យកាយសម្បទានេះ ជូនសាមីជន ដើម្បីប្រើប្រាស់ជាផ្លូវការ ។

ប្រការ៧: ម្ចាស់សហគ្រាសត្រូវបង់ថ្លៃឈ្នួល សំរាប់ការពិនិត្យកាយសម្បទា នៃនិយោជិតរបស់ខ្លួន ដែលបានកំណត់ក្នុងប្រការ៥ខាងលើ ទៅតាមករណីនីមួយៗ ។

ប្រការ៨: ការប្រព្រឹត្តល្មើស ឬ មិនអនុវត្តតាម បទបញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬ ទទួលទោស ដូចមានចែងក្នុងមាត្រា ២៨៦ និង ២៨៨ នៃច្បាប់ការងារ ។

ប្រការ៩: ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្ត ចាប់ពីពេលចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាល

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច
ការងារ និងអតីតយុទ្ធជន

វេជ្ជ.ឈា.ថាង

ស៊ុយ.សែម

ចម្លងជូន :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួងមហាផ្ទៃ
- "ដើម្បីជូនជ្រាប"
- ក្រសួងពត៌មាន
- "ជួយផ្សព្វផ្សាយអោយបានទូលំទូលាយ"
- ភពកិច្ច
- កាលប្បវត្តិ-ឯកសារ

លេខ : ៧/

ភ្នំពេញ, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ

ហ៊ាំង.ស៊ីថា